**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១៥៥ ទស

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់ មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមការងារចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងបង្កើតនីតិវិធីក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានា និងបង្កើនប្រសិទ្ធភាព និងគុណភាពសេវាកម្ម



ដីឡូត៍លេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

ទេសចរណ៍ឲ្យកាន់តែប្រសើរឡើង។

**ប្រការ ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ដែលកំពុងប្រកបវិជ្ជាជីវៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ច និងនីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ៣._**

ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ជាសមត្ថកិច្ចរបស់ក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍។

**ប្រការ ៤._**

ការព្រមាន និងការពិន័យផ្សេងៗត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ តាមរយៈការស្នើសុំរបស់ក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ ដោយផ្អែកតាមរបាយការណ៍របស់ក្រុមត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត។

**ប្រការ ៥._**

ការចុះត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងការអនុវត្តវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវធ្វើឡើងដោយមន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬ មន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត។

ករណីពិនិត្យឃើញថា មគ្គុទ្ទេសក៍ទេសចរណ៍ណាមួយបានអនុវត្តផ្ទុយពីគោលការណ៍ និងការណែនាំដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ មន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត ត្រូវរាយការណ៍ជាបន្ទាន់មកក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

មន្ត្រីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍ និង/ឬមន្ត្រីទទួលបន្ទុកត្រួតពិនិត្យមគ្គុ-ទ្ទេសក៍ទេសចរណ៍រាជធានី ខេត្ត ត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងលិខិតអនុញ្ញាតឲ្យបំពេញបេសក-កម្មរាល់ពេលចុះត្រួតពិនិត្យតាមគោលដៅ។

**ប្រការ ៦._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានពិន្ទុ ដូចខាងក្រោម៖

- អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្ន មានពិន្ទុសរុបចំនួន ០៥
- អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដែលទទួលបានលើកដំបូង មានពិន្ទុសរុបចំនួន ០៨
- អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ មានពិន្ទុសរុបចំនួន ១០។

**ប្រការ ៧._**

ពិន្ទុសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ អាចនឹងត្រូវបានដកជាបន្តបន្ទាប់រហូតឈានដល់ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ ដោយផ្អែកលើសកម្មភាព និងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៨._**

រាល់ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ និងបញ្ជាក់អំពីមូលហេតុច្បាស់លាស់អំពីកំហុសដែលមគ្គុទ្ទេសក៍ទេសចរណ៍នោះបានប្រព្រឹត្ត។

**ប្រការ ៩._**

ក្រោយទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចជាលាយល័ក្ខអក្សរក្នុងការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ដែលមិនសុខចិត្តអាចធ្វើការតវ៉ាមកក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិវិញក្នុងរយៈពេល ១៤ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចជាលាយល័ក្ខអក្សរក្នុងការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍។

## ជំពូកទី៣
## ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

**ប្រការ ១០._**

ការព្រមានចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវបានអនុវត្តដូចខាងក្រោម៖

- មគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ (បណ្តោះអាសន្ន ឬពេញសិទ្ធិ) បានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៣ នឹងត្រូវទទួលការព្រមានលើកទី០១។
- ករណីដែលបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៤ នឹងត្រូវទទួលការព្រមានលើកទី០២។

- ករណីមិនរាងចាល និងបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៥ នឹងត្រូវទទួលរងការព្រមានលើកទី ០៣។ ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្ន នឹងមិនអាចទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិឡើយ។

**ប្រការ ១១._**

ការបញ្ចុះថ្នាក់ និងការព្យួរអាជ្ញាបណ្ណទេសចរណ៍ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ ត្រូវបានអនុវត្តដូចខាងក្រោម៖

- មគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិ បានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៦ អាចនឹងត្រូវទទួលការពិន័យតាមរយៈការបញ្ចុះថ្នាក់ពីអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិមកជាអាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្ន ក្រោយមានការពិនិត្យលើស្ថានភាពកំហុសជាក់ស្ដែងពីក្រុមការងារត្រួតពិនិត្យគុណភាពមគ្គុទ្ទេសក៍ទេសចរណ៍។
- ករណីបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៧ នឹងត្រូវទទួលការពិន័យតាមរយៈការព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៣ខែ ដោយមិនអនុញ្ញាតឲ្យប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ឡើយ។
- ករណីមិនរាងចាល និងបានប្រព្រឹត្តកំហុសឈានដល់ការដកពិន្ទុចំនួន ០៨ នឹងត្រូវទទួលការពិន័យតាមរយៈការព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៦ខែ ដោយមិនអនុញ្ញាតឲ្យប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ឡើយ។

**ប្រការ ១២._**

ការលុបអាជ្ញាបណ្ណទេសចរណ៍ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទទួលបានអាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិត្រូវបានអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងឡាយណាដែលបានប្រព្រឹត្តិកំហុសរហូតឈានដល់ការដកពិន្ទុលើសពី ០៨ឡើងទៅ។

## ជំពូកទី៤
## ការទទួលបានពិន្ទុដែលបាត់បង់ និងការលើកទឹកចិត្ត

**ប្រការ ១៣._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានអនុវត្តវិជ្ជាជីវៈត្រឹមត្រូវ និងមិនបានប្រព្រឹត្តិនូវកំហុសធ្ងន់ណាមួយដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចនឹងទទួលបានការលើកទឹកចិត្តតាមរយៈការផ្ដល់ជូនជារង្វាន់ មេដាយ ឬប័ណ្ណសរសើរដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

យន្តការនៃការលើកទឹកចិត្តដល់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ ១៤._**

ក្នុងរយៈពេល ០៦ខែ បន្ទាប់ពីទទួលបានលិខិតព្រមាន ឬសេចក្តីសម្រេចដកពិន្ទុពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រសិនបើមគ្គុទ្ទេសក៍ទេសចរណ៍នោះ ពុំបានអនុវត្តខុសនឹងអ្វីដែលបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះទេ មគ្គុទ្ទេសក៍ទេសចរណ៍នោះនឹងទទួលបានពិន្ទុ ០១វិញ ទៅក្នុងអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួន។

ការផ្តល់ពិន្ទុ ០១ វិញនេះ នឹងត្រូវបានអនុវត្តជារៀងរាល់ ០៦ខែម្តង រហូតទទួលបានពិន្ទុពេលលេញ ប្រសិនបើ មគ្គុទ្ទេសក៍ទេសចរណ៍នោះមិនបានប្រព្រឹត្តខុសតាមការកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ ១៥._**

ពិន្ទុដែលបានបាត់បង់ដោយសារការអនុវត្តមិនបានត្រឹមត្រូវតាមការកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ មិនត្រូវបានផ្តល់ជូនវិញទេ ទោះបីមានការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មីឡើងវិញក៏ដោយ។

**ប្រការ ១៦._**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលអាជ្ញាបណ្ណទេសចរណ៍ត្រូវបានលុប ហើយមានបំណងបន្តវិជ្ជាជីវៈជាមគ្គុទ្ទេសក៍ទេសចរណ៍វិញ ត្រូវមកដាក់ពាក្យសុំចូលសិក្សាវគ្គវិក្រឹត្យការមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងរយៈពេល ០៦ខែ យ៉ាងតិចក្រោយពីដកអាជ្ញាបណ្ណទេសចរណ៍រួច។

**ប្រការ ១៧._**

ការព្រមាន ការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ដែលសម្រេចដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចធ្វើឲ្យមគ្គុទ្ទេសក៍ទេសចរណ៍រួចផុតពីពិន័យអន្តរកាល និងការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការទទួលខុសត្រូវរដ្ឋប្បវេណីនោះទេ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៨._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.**_

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-សាលារាជធានី ខេត្ត
-ដូចប្រការ១៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៤

## ស្តីពី

## នីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈ របស់មគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

| លរ | សកម្មភាពពិន័យអប្បរមា | ពិន្ទុ |
|---|---|---|
| ១ | មគ្គុទេសក៏ទេសចរណ៏មិនអនុវត្តតាមបទបញ្ញត្តិ និងច្បាប់ជាធរមាន។ | ៥ |
| ២ | មគ្គុទ្ទេសក៏ទេសចរណ៏មិនស្លៀកពាក់ឯកសណ្ឋាន ឬអាជ្ញាបណ្ណក្នុងពេលបំពេញការងារ។ | ៣ |
| ៣ | មគ្គុទ្ទេសក៏ទេសចរណ៏មិនបានពាក់ស្លាកឈ្មោះក្នុងពេលបំពេញការងារ។ | ១ |
| ៤ | មគ្គុទ្ទេសក៏ទេសចរណ៏មានអាកប្បកិរិយា ឬសម្តីមិនថ្លៃថ្នូរធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬមុខមាត់ប្រទេសជាតិ។ | ២ |
| ៥ | មគ្គុទ្ទេសក៏ទេសចរណ៏ដែលនិយាយប៉ះពាល់ ឬប្រមាថដល់ការគោរពលើជំនឿសាសនានៃប្រជាពលរដ្ឋ ឬជាតិសាសន៍ណាមួយ។ | ២ |
| ៦ | មគ្គុទ្ទេសក៏ទេសចរណ៏បោះ ឬពង្រាយសម្រាមខណៈពេលកំពុងបំពេញការងារ។ | ១ |
| ៧ | មគ្គុទ្ទេសក៏ទេសចរណ៏បណ្តែតបណ្តោយឲ្យទេសចរធ្វើការបំផ្លិចបំផ្លាញធនធានទេសចរណ៏ដូចជាតំបន់បេតិកភណ្ឌវប្បធម៌ ធម្មជាតិ និងតំបន់ទាក់ទាញទេសចរណ៏។ | ៣ |
| ៨ | មគ្គុទ្ទេសក៏ទេសចរណ៏ផ្តល់ព័ត៏មានដល់ភ្ញៀវដោយមធ្យោបាយផ្សេងៗ ឆ្ពោះទៅរកសេវាកម្ម ឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ២ |
| ៩ | មគ្គុទ្ទេសក៏ទេសចរណ៏ទាក់ទាញ ឬបញ្ចុះបញ្ចូលភ្ញៀវដោយមធ្យោបាយ ផ្សេងៗឆ្ពោះទៅរកសេវាកម្ម ឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ៣ |
| ១០ | មគ្គុទ្ទេសក៏ទេសចរណ៏នាំភ្ញៀវដោយមធ្យោបាយផ្សេងៗទៅរកសេវាកម្មឬប្រព្រឹត្តិសកម្មភាពដែលមានការហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាន ឬអ្នកគ្រប់គ្រងតំបន់។ | ៥ |
| ១១ | មគ្គុទ្ទេសក៏ទេសចរណ៏នាំភ្ញៀវទៅកាន់ទីតាំងអាជីវកម្មណាមួយដែលផ្តល់នូវសេវាកម្មឬធ្វើអាជីវកម្មបោកប្រាស់ ឬក្លែងបន្លំ ឬរំលោភលើសេចក្តីទុកចិត្តរបស់ភ្ញៀវ ឬធ្វើការឃុបឃិតជាមួយឈ្មួញឬទីតាំងអាជីវកម្មណាមួយដោយជូនភ្ញៀវទៅទិញទំនិញ ឬវត្ថុអនុស្សាវរីយ៍ដោយតម្លៃមិនសមរម្យ។ | ៥ |
| ១២ | មគ្គុទ្ទេសក៏ទេសចរណ៏បង្ខិតបង្ខំភ្ញៀវទៅកាន់ទីតាំងអាជីវកម្មណាមួយដើម្បីទទួលបានផលប្រយោជន៏ផ្ទាល់ខ្លួនដោយភ្ញៀវមិនពេញចិត្ត។ | ៤ |
| ១៣ | មគ្គុទ្ទេសក៏ទេសចរណ៏ស្នើសុំភ្ញៀវឲ្យផ្តល់កម្រៃឲ្យខ្លួនតាមគ្រប់មធ្យោបាយឬក៏ផ្តល់សេវាកម្មឲ្យភ្ញៀវមិនគ្រប់តាមស្តង់ដាដោយសារភ្ញៀវមិនផ្តល់កម្រៃបន្ថែមឲ្យខ្លួន។ | ៣ |
| ១៤ | មគ្គុទ្ទេសក៏ទេសចរណ៏បំភិតបំភ័យឬបោកបញ្ឆោតទេសចរដើម្បីឲ្យពួកគាត់បង់ប្រាក់បន្ថែម | ៣ |

| | | |
|---|---|---|
| | ទៅលើសេវាកម្មណាមួយ។ | |
| ១៥ | មគ្គុទ្ទេសក៍ទេសចរណ៍ចាកចោល ឬបោះបង់ភ្ញៀវដោយមិនទាន់បានបញ្ចប់ភារកិច្ច ឬគេចវេសមិនទទួលខុសត្រូវក្នុងស្ថានភាពគ្រោះថ្នាក់ ឬហានីភ័យ ណាមួយ។ | ៥ |
| ១៦ | មគ្គុទ្ទេសក៍ទេសចរណ៍លេងល្បែងស៊ីសង ឬនាំភ្ញៀវលេងល្បែងស៊ីសងខុសច្បាប់ខណៈពេលកំពុងបំពេញការងារ។ | ៣ |
| ១៧ | មគ្គុទ្ទេសក៍ទេសចរណ៍មានជម្លោះជាមួយអ្នកបើកបររថយន្តដឹកភ្ញៀវ ឬភ្ញៀវ ឬអាជ្ញាធរមានសមត្ថកិច្ច ឬបុគ្គលផ្សេងៗនៅចំពោះមុខភ្ញៀវខណៈពេលកំពុងបំពេញការងារ។ | ២ |
| ១៨ | មគ្គុទ្ទេសក៍ទេសចរណ៍ជក់បារីនៅចំពោះមុខភ្ញៀវ ខណៈពេលកំពុងបំពេញការងារ។ | ១ |
| ១៩ | មគ្គុទ្ទេសក៍ទេសចរណ៍ប្រើប្រាស់គ្រឿងស្រវឹង ខណៈពេលកំពុងបំពេញការងារ។ | ៤ |
| ២០ | មគ្គុទ្ទេសក៍ទេសចរណ៍មានការពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀន ឬផ្ដល់ព័ត៌មាន ឬធ្វើការទាក់ទាញ ឬបញ្ចុះបញ្ចូលដល់ភ្ញៀវឆ្ពោះទៅរកកន្លែងប្រើប្រាស់សារធាតុញៀនខុសច្បាប់។ | ១០ |